

យ៉េកសួរ ៖ «នៅថ្ងៃឈប់សម្រាក តើអ្នកទៅដើរលេងនៅភ្នំពេញសប្បាយទេ?»
រតនាឆ្លើយ ៖ «ចាស! សប្បាយខ្លាំងណាស់!
ទោះបីជាពួកយើងត្រូវទៅសាលាជាមួយមីងរបស់ពួកយើងក៏ដោយ»។



យ៉េកសួរទាំងឆ្ងល់ ៖ «អ្នកត្រូវទៅសាលាក្នុងថ្ងៃឈប់សម្រាកទៀត?»
ធ្វើអ៊ីចឹង មិនសប្បាយទេមើលទៅ!
«អូ! សប្បាយទេតើ! អ្នកមីងដារិនធ្វើការនៅឯសាលាសម្រាប់ក្មេងដែលត្រូវការ
ការអប់រំពិសេស។ នៅទីនោះ ពួកយើងបានស្គាល់មិត្តភក្តិល្អៗជាច្រើន»។



មករានិយាយ ៖ «នៅម៉ោងសិល្បៈ ខ្ញុំបានអង្គុយជិតក្មេងប្រុសម្នាក់ឈ្មោះ ទី។
គាត់កើតមក ដោយពិការដៃទាំងសងខាង»។
យ៉េកក៏សួរ ៖ «ម៉ោងសិល្បៈ? តើគាត់គូររូបយ៉ាងណាទៅ បើពិការដៃ?»
«គាត់អាចគូរបានទេតើ! គ្រាន់តែតាមវិធីផ្សេងពីយើង។ គាត់ប្រើមាត់ដើម្បីគូររូប»។
យ៉េកនិយាយ ៖ «អូ! អស្ចារ្យណាស់!»



«នៅល្ងាចនោះ ខ្ញុំ និងរតនាបានសាកល្បងធ្វើដូចគាត់ដែរ ប៉ុន្តែយើងបានធ្វើឱ្យ
ថ្នាំពណ៌ប្រឡាក់គ្រប់ទីកន្លែង»។



រតនានិយាយ ៖ «ខ្ញុំបានជួបក្មេងស្រីម្នាក់ឈ្មោះ ចិន្តាដែលនាងពិការភ្នែក។
កាលនោះ នាងកំពុងអានសៀវភៅ»។
យ៉េកសួរ៖ «អានសៀវភៅ? តើនាងអានសៀវភៅយ៉ាងណាទៅ បើនាងពិការភ្នែក?»



រតនាក៏បកស្រាយ ៖ «នាងអាចអានបានតើ គ្រាន់តែតាមវិធីផ្សេងពីយើង។ សៀវភៅរបស់នាង គឺសរសេរឡើងដោយប្រើអក្សរស្ទាប។ តួអក្សរនីមួយៗផុសឡើងមក ហើយនាងអានដោយប្រើម្រាមដៃរបស់នាង»។

យ៉េកនិយាយ ៖ «អូ! អស្ចារ្យណាស់!»



«មានក្មេងខ្លះដែលជិះរទេះ បានហៅពួកយើងឱ្យលេងបាល់បោះជាមួយពួកគាត់»។
យ៉េកសួរ ៖ «បាល់បោះ! តើពួកគាត់អាចលេងបាល់បោះតាមរបៀបណាទៅ?»
«តើអ្នកទាំងពីរ ត្រូវជិះរទេះដូចពួកគាត់ដែរឬទេ?»



«ពួកគាត់អាចលេងបានទេតើ គ្រាន់តែតាមវិធីផ្សេងពីយើង។ ពួកយើងរត់ ឯពួកគាត់វិញបង្វិលកង់រទេះ។ ពួកគាត់បោះចូលសឹងតែរាល់ដង!»
យ៉េកនិយាយ៖ «អូ! អស្ចារ្យណាស់!»



«ពួកយើងបានជួបក្មេងប្រុសម្នាក់ឈ្មោះ មេសាដែលពិការត្រចៀក។
ពួកយើងបានលេងល្បែងសែម៉ុនសេជាមួយគ្នា»។
យ៉េកសួរ៖ «សែម៉ុនសេ! តើធ្វើយ៉ាងណាទើបគាត់ដឹងថាខ្លួនត្រូវធ្វើអ្វី
បើគាត់ស្ដាប់មិនឮផងហ្នឹង?»
«គាត់អាចស្ដាប់ឮបាន គ្រាន់តែតាមវិធីផ្សេងពីយើង។ គាត់ឈរនៅខាងមុខ ដូច្នេះគាត់អាច
មើលមាត់របស់អ្នកគ្រូ ធ្វើយ៉ាងនេះគាត់អាច "ស្ដាប់" អ្នកគ្រូយល់បាន»។



«ដំបូង មីងដារិននិយាយដោយសំឡេងធម្មតា ដូច្នេះយើងទាំងអស់គ្នាអាចធ្វើតាមគាត់បាន។ តែក្រោយមក គាត់ខ្សឹបដោយមិនបញ្ចេញសំឡេងទេ។ ពេលនោះយើងមិនអាចស្ដាប់គាត់ឮ ហើយក៏មិនដឹងថាគួរធ្វើអ្វីដែរ មានតែមាសទេដែលដឹង និងយល់»។

យ៉េកនិយាយ៖ «អូ! អស្ចារ្យណាស់!»



នៅយប់នោះ រតនាបានគិតដល់សំណាង ដែលទើបប្តូរចូលថ្នាក់របស់នាង។
គាត់មានជំងឺអូទីសឹម។ គាត់មិនចូលចិត្តលេងល្បែងទេ ហើយក៏មិននិយាយច្រើនដែរ។
ក្មេងដទៃទៀតនៅក្នុងថ្នាក់គិតថាគាត់ជាក្មេងចម្លែក។
រតនាគិតថា ៖ «ប្រហែលជាសំណាង ដូចជាក្មេងៗនៅសាលារបស់មីងដារិនអ៊ីចឹង។
គាត់អាច គ្រាន់តែតាមវិធីផ្សេង»។



នៅថ្ងៃបន្ទាប់ រតនាបានសួរសំណាង ថាតើគាត់ចាប់អារម្មណ៍លើរឿងអ្វី?
សំណាងឆ្លើយ៖ «លំហ»។
បន្ទាប់មក គាត់ក៏ចាប់ផ្តើមប្រាប់រតនាពីរឿងរ៉ាវជាច្រើនដែលទាក់ទងនឹងភព
និងអវកាសយានិក។



ក្មេងដទៃក៏ចាប់ផ្តើមចូលរួមស្តាប់ផងដែរ។
ក្មេងម្នាក់បាននិយាយ៖ «អូ! អស្ចារ្យណាស់! អ្នកដឹងពីរឿងលំហច្រើនមែនទែន!
តើអ្នកចង់លេងល្បែងអវកាសយានិក និងមនុស្សភពផ្សេងដែរឬទេ?»
‹‹បាទចង់តើ›› សំណាងឆ្លើយ។



សំណាងលេងរហូតដល់ឮសំឡេងជួង។ ពេលដែលពួកគាត់កំពុងដើរទៅថ្នាក់រៀនវិញ
រតនាបានឮមិត្តរួមថ្នាក់ពីរនាក់និយាយគ្នា។
ម្នាក់និយាយ៖ «តាមពិតគាត់មិនសូវជាចម្លែកប៉ុន្មានទេ»។
ម្នាក់ទៀតក៏បន្តឆ្លើយ៖ «មែនហើយៗ! គ្រាន់តែគាត់មានវិធីផ្សេងពីយើង»។
រតនា និងមករាក៏និយាយទៅកាន់អ្នកទាំងអស់គ្នា៖ «អូ! អស្ចារ្យណាស់ៗ!»។




# យើងអាច គ្រាន់តែតាមវិធីផ្សេងគ្នា


អ្នកនិពន្ធ៖TukTuk

អ្នកគំនូរ៖ ហ៊ិន ឆវិន